# តើភាសាបារាំងមានសារសំខាន់សម្រាប់អ្នកសិក្សាដូចម្តេចខ្លះ?

## L'IMPORTANCE DE L'APPRENTISSAGE DU FRANÇAIS

ភាសាបារាំងគឺជាភាសាបរទេសដែលត្រូវបានគេចូលចិត្តនិយាយ និងសិក្សាយ៉ាងទូលំទូលាយនៅលើពិភពលោកដូចជាភាសាអង់គ្លេសដែរ។ ភាសាបារាំងស្ថិតនៅលំដាប់ទី៩នៃភាសាបរទេស ដែលគេនិយាយច្រើនជាងគេនៅលើពិភពលោក ហើយដែលបច្ចុប្បន្ននេះមានប្រទេសដែលនិយាយភាសាបារាំងចំនួន៦៨ប្រទេស និងរដ្ឋាភិបាល ដែលមានមនុស្សជាង២០០លាននាក់កំពុងនិយាយភាសានេះនៅលើទ្វីបទាំងប្រាំ។

សម្រាប់ប្រទេសកម្ពុជាយើង ភាសាបារាំងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដោយសារប្រទេសយើងជាសមាជិកក្រុមប្រទេសនិយាយភាសាបារាំង និងដោយសារធ្លាប់មានទំនាក់ទំនងវប្បធម៌ និងប្រវត្តិសាស្ត្រជាមួយគ្នាផង។ ស្របតាមកម្មវិធីសិក្សារបស់ក្រសួងអបរំ យុវជន និងកីឡា ភាសាបារាំងជាជីវភាសាដែលអនុញ្ញាតឱ្យបង្រៀនចាប់ពីអនុវិទ្យាល័យឡើងទៅ។ ប៉ុន្តែនៅក្នុងកម្រិតនេះសិស្សានុសិស្សរបស់យើង មើលពុំសូវឃើញទេនូវសារសំខាន់របស់ភាសាបារាំង ដែលខ្លះខ្ជាយពេលវេលា ពុំខិតខំសិក្សាភាសានេះឡើយ។ តាមពិតនៅកម្រិតឧត្តមសិក្សា ភាសាបារាំងមានសារសំខាន់ និងភាពចាំបាច់ណាស់ព្រោះថាភាសានេះត្រូវបានសិក្សាយ៉ាងស៊ីជម្រៅនៅតាមសាកលវិទ្យាល័យមួយចំនួន សម្រាប់ជាភាសាយាន និងភាសាបច្ចេកទេស។ ខាងក្រោមនេះគឺជាគ្រឹះស្ថានឧត្តមសិក្សាដែលប្រើប្រាស់ភាសាបារាំង :

- វិទ្យាស្ថានជាតិអប់រំ
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

ក្នុងគោលបំណងល្អ សម្រាប់បង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សនៅពេលចូលទៅសិក្សានៅក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនេះ គឺត្រូវត្រៀមលក្ខណៈសម្បត្តិជាមុន ដោយត្រូវខិតខំសិក្សាភាសានេះឱ្យបានកម្រិតសមល្មមតាំងពីនៅមធ្យមសិក្សាមក។ ចំណេះដឹងជាមូលដ្ឋាននៃភាសាបារាំងមានសារសំខាន់នឹងជួយយើងឱ្យឈានទៅចាប់យកជំនាញឯកទេសនានា ហើយក៏នឹងអាចឈានទៅចាប់យកភាសាបរទេសមួយផ្សេងទៀត មានជាអាទិ៍ភាសាអេស្ប៉ាញ៉ុល អ៊ីតាលី ប៉័ទុយហ្គាល់ និងភាសាអង់គ្លេសផងដែរ ព្រោះថាភាសាបារាំងបានផ្តល់ជាង៥០% នៃវាក្យស័ព្ទរបស់ភាសាអង់គ្លេសបច្ចុប្បន្ន។ ការដែលយើងចេះភាសាបរទេសកាន់តែច្រើន ធ្វើឱ្យសមត្ថភាពនៃការស្រាវជ្រាវ និងការចាប់យកចំណេះដឹងថ្មីរបស់យើង កាន់តែមានវិសាលភាពធំទូលាយដែលជាកត្តានាំយើងឈានទៅ ទទួលភាពជោគជ័យនៅក្នុងការសិក្សា និងអាចបន្តការសិក្សាបានខ្ពស់រហូតដល់ថ្នាក់បណ្ឌិត។

ក្រៅពីការសិក្សានៅកម្រិតឧត្តមសិក្សានៅក្នុងប្រទេស និស្សិតដែលពូកែភាសាបារាំង នឹងមានឱកាសជាអាទិភាពក្នុងការទទួលអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសបារាំង និងក្រុមប្រទេសនិយាយភាសាបារាំង ជាពិសេសអាចទៅបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យល្បីៗ ឬនៅក្នុងសាលាសេដ្ឋកិច្ចធំៗ ដែលមានចំណាត់ថ្នាក់ល្បីនៅក្នុងគ្រឹះស្ថានជាន់ខ្ពស់នៃសហព័ន្ធអឺរ៉ុប និងក្នុងភិពភលោក។

បច្ចុប្បន្ននេះ យើងកំពុងស្ថិតនៅក្នុងយុគសម័យនៃសកលភាវូបនីយកម្ម។ ឥទ្ធិពលនេះទាមទារឱ្យយើងត្រូវតែផ្សារភ្ជាប់ខ្លួនទៅនឹងការិវិវត្តប្រែប្រួលនៃពិភពលោក ទៅនឹងការរីកចម្រើននៃវិទ្យាសាស្ត្រ។ ទាំងនេះហើយដែលជំរុញឱ្យសិស្សានុសិស្សយើងខិតខំសិក្សាភាសាបរទេសឱ្យបានច្បាស់លាស់ក្នុងនោះដែរការសិក្សាភាសាបារាំងមិនគួរ សិស្សានុសិស្សយើងមើលរំលងឡើយ។

លើសពីនេះភាសាបារាំងត្រូវបានគេទទួលស្គាល់ថាជានិមិត្តរូបនៃវប្បធម៌ និងជាភាសានៃទំនាក់ទំនងអន្តរជាតិ ព្រោះថាភាសានេះត្រូវបានគេប្រើប្រាស់ជាផ្លូវការនៅអង្គការសហប្រជាជាតិ នៅក្នុងសហព័ន្ធអឺរ៉ុប នៅអង្គការយូណេស្កូ អង្គការអូតង់ គណៈកម្មការអន្តរជាតិអូឡាំពិច កាកបាទក្រហមអន្តរជាតិ និងនៅសាលាច្បាប់អន្តរជាតិជាច្រើនជាពិសេសទៅទៀត ភាសាបារាំងជាភាសាផ្លូវការដែលគេប្រើប្រាស់នៅទីក្រុងចំនួន ៣ដែលមានអាសនៈនៅសហព័ន្ធអឺរ៉ុប : ទីក្រុងស្ត្រាស្បួ ១រុតរាសប៊្យរងបុ ទីក្រុងព្រុចសែល (Bruxelles) ទីក្រុងលុចសម្បួរ (Luxembourg)។

ជារៀងរាល់ឆ្នាំ ប្រទេសបារាំងទទួលភ្ញៀវទេសចរណ៍បានចំនួន៧០លាននាក់ គឺជាតួលេខខ្ពស់ជាងគេបំផុតនៅលើពិភពលោក។ ជាមួយការចេះភាសាបារាំងកម្រិតដំបូង វាជាការប្រសើរណាស់ក្នុងការទៅទស្សនាទីក្រុងប៉ារីស និងគ្រប់តំបន់ក្នុងប្រទេសបារាំង ទស្សនាភាពស្រស់ស្អាតនៃឆ្នេរសមុទ្រអាសៀ កំពូលភ្នំអាល់ ព្រៃភ្នំនៃ តំបន់ប្រីតាញ ហើយនឹងការយល់វប្បធម៌ ចិត្តគំនិត និងសិល្បៈនៃការរស់នៅរបស់ជនជាតិបារាំង។ ភាសាបារាំងក៏មានប្រយោជន៍ នៅពេលគេទៅទស្សនា ឬទំនាក់ទំនងការងារជាមួយប្រទេសអាព្រិច ប្រទេសស្វីស ប្រទេសកាណាដា ម៉ូណាកូ កោះសេសែល ជាដើម ពីព្រោះប្រទេសទាំងនេះប្រើប្រាស់ភាសាបារាំង។

ដោយសង្ខេប ភាសាបារាំងត្រូវបានគេចាត់ទុកជាភាសានៃសេចក្តីស្រឡាញ់ ព្រោះជាភាសាដ៏ល្អមួយដែលមានលក្ខណៈសម្បូរបែបសម្រាប់គ្រប់ផ្នែក ទាំងផ្នែកសិល្បៈនៃការធ្វើម្ហូបអាហារ ម៉ូតសម្លៀកបំពាក់ ល្ខោន សិល្បៈ របាំ និង ស្ថាបត្យកម្ម ហើយក៏ជាភាសាមួយដែលពិរោះសម្រាប់ត្រចៀកដែលទាក់ទាញទឹកចិត្តអ្នកសិក្សា ឱ្យជក់ចិត្តហើយដែលអ្នកខ្លះទៀតហៅភាសាបារាំងថាភាសានៃសេចក្តីស្នេហា។ ជាមោទនភាពណាស់សម្រាប់ជនជាតិកម្ពុជាដែលចេះនិយាយភាសាបារាំង ព្រោះគេតែងយល់ថាមានការលំបាកក្នុងការសិក្សាភាសានេះ ហើយប្រើពេលវេលាយូរទៀតផង។ ប៉ុន្តែនេះជាទស្សនៈយល់ច្រលំសោះ ព្រោះថាតាមវិធីសាស្ត្រទំនើបបច្ចុប្បន្ននេះ ការសិក្សាភាសាបារាំងត្រូវបានកែសម្រួលឱ្យកាន់តែមានលក្ខណៈប្រសើរ ដោយរួមបញ្ចូលសមត្ថភាពទាំងបួន គឺមានន័យថាប្រើរយៈពេលខ្លីហើយរៀនចាប់ចេះនិយាយទៀតផង។

**អ៊ុក ឧត្តរៈ** អធិការភាសាបារាំង វិទ្យាស្ថានជាតិអប់រំ